នស/រកត/០៥១៥/៤០៣

# ព្រះរាជក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៨/០០៦ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជីវសុវត្ថិភាព
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

## ប្រកាសបទ្ទាប់

### ជំពូកទី១
### បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដែលសរសេរជាអក្សរកាត់ថា **ក.ជ.អ.ច.** ដើម្បីលើកកម្ពស់ការអភិវឌ្ឍដោយចីរភាព សំដៅជានាបាននូវតុល្យភាពរវាង សេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ជំពូកទី២
### សមាសភាពរបស់ ក.ជ.អ.ច.

**មាត្រា២ .-**

**ក.ជ.អ.ច.** មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា | ប្រធានកិត្តិយស |
| - រដ្ឋមន្ត្រីក្រសួងបរិស្ថាន | ប្រធាន |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១រូប | អនុប្រធានទី១ |
| - រដ្ឋលេខាធិការក្រសួងបរិស្ថាន ១រូប | អនុប្រធានទី២ |
| - រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការពារជាតិ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងផែនការ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងព័ត៌មាន ១រូប | សមាជិក |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ក្រសួងព្រះបរមរាជវាំង

- រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងសុខាភិបាល ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងសាធារណៈការនិងដឹកជញ្ជូន ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងទេសចរណ៍ ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងកិច្ចការនារី ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ ១រូប សមាជិក
- រដ្ឋលេខាធិការរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សមាជិក
- អគ្គលេខាធិការឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ សមាជិក
- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក
- អគ្គលេខាធិការគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សមាជិក
- អគ្គលេខាធិការក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ សមាជិក
- អគ្គលេខាធិការគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ សមាជិក
- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត សមាជិក
- អគ្គលេខាធិការគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា សមាជិក
- អគ្គលេខាធិការ **ក.ជ.អ.ច.** សមាជិកអចិន្ត្រៃយ៍។

សមាសភាពជាក់ស្តែងរបស់ **ក.ជ.អ.ច.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## តួនាទីនិងភារកិច្ចរបស់ ក.ជ.អ.ច.

**មាត្រា៣ .-**

**ក.ជ.អ.ច.** មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- រៀបចំ ណែនាំ សម្របសម្រួលការអនុវត្ត និងវាយតម្លៃគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធី និងគម្រោង ពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព
- លើកកម្ពស់ការបញ្ជ្រាបការអភិវឌ្ឍដោយចីរភាពទៅក្នុងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធី និងគម្រោងពាក់ព័ន្ធនានា ដោយ

សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ

- កៀរគរធនធាន សម្រាប់អនុវត្តគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធី និងគម្រោង ពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព
- កសាងនិងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន គ្រឹះស្ថានសិក្សាស្រាវជ្រាវ និងអ្នកពាក់ព័ន្ធផ្សេងទៀត សំដៅគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព
- ជំរុញនិងលើកកម្ពស់ការសិក្សាស្រាវជ្រាវ ការអប់រំ ការបណ្តុះបណ្តាល ការផ្លាស់ប្តូរបច្ចេកវិទ្យា និងការផ្សព្វផ្សាយពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព
- លើកយោបល់ ជំហរ និងយុទ្ធសាស្ត្រជាតិ សម្រាប់ចូលរួមក្នុងកិច្ចព្រមព្រៀង កិច្ចប្រជុំ និងការចរចាអន្តរជាតិនានា ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព
- ពិនិត្យនិងអនុម័តរបាយការណ៍ផ្លូវការនានារបស់ជាតិ ដែលតម្រូវឱ្យរៀបចំ នៅក្រោមកិច្ចព្រមព្រៀងបរិស្ថានពហុភាគីនានា ដែលកម្ពុជាជាសមាជិក
- គ្រប់គ្រងព័ត៌មាននិងការប្រាស្រ័យទាក់ទងពាក់ព័ន្ធនឹងការងារអភិវឌ្ឍន៍ដោយចីរភាព
- ដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការងារសេដ្ឋកិច្ចបៃតង ការប្រែប្រួលអាកាសធាតុ ការអភិរក្សជីវៈចម្រុះ និងជីវសុវត្ថិភាព
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីរាជរដ្ឋាភិបាល។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ ក.ជ.អ.ច.

**មាត្រា៤ ._**

**ក.ជ.អ.ច.** ត្រូវប្រជុំយ៉ាងតិច១ដង ក្នុង១ឆ្នាំ តាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធានតាមការប្រគល់សិទ្ធិ។ ក្នុងករណីចាំបាច់ ប្រធាន **ក.ជ.អ.ច.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន មន្ត្រីជំនាញ អ្នកឯកទេស ឬផ្នែកឯកជន ចូលរួមពិគ្រោះយោបល់ និងសិក្សាស្រាវជ្រាវលើរាល់បញ្ហា ដែលទាក់ទងនឹងក្របខ័ណ្ឌការងាររបស់ខ្លួន។

ក្នុងករណីដែលប្រធានអវត្តមាន អនុប្រធានមួយរូបអាចដឹកនាំកិច្ចប្រជុំ **ក.ជ.អ.ច.** ជំនួសតាមការប្រគល់សិទ្ធិពីប្រធាន។

**មាត្រា៥ ._**

**ក.ជ.អ.ច.** មានគណៈកម្មាធិការប្រតិបត្តិមួយ ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងបរិស្ថាន | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១រូប | អនុប្រធានទី១ |
| - រដ្ឋលេខាធិការក្រសួងបរិស្ថាន ១រូប | អនុប្រធានទី២ |
| - រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម ១រូប | សមាជិក |



ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ក្រសួងព្រះបរមរាជវាំង

- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងសាធារណៈការនិងដឹកជញ្ជូន ១រូប សមាជិក
- អគ្គលេខាធិការ **គ.ជ.អ.ច.** សមាជិកអចិន្ត្រៃយ៍។

សមាសភាពជាក់ស្តែងរបស់គណៈកម្មាធិការប្រតិបត្តិ **គ.ជ.អ.ច.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៦ .-**

គណៈកម្មាធិការប្រតិបត្តិ **គ.ជ.អ.ច.** ត្រូវប្រជុំ ដើម្បីត្រួតពិនិត្យនិងបូកសរុបការងារនិងធ្វើរបាយការណ៍ជូន **គ.ជ.អ.ច.** យ៉ាងតិច៣ (បី) ខែម្តង ។

**មាត្រា៧ .-**

បែបបទនិងនីតិវិធីការងាររបស់ **គ.ជ.អ.ច.** និងគណៈកម្មាធិការប្រតិបត្តិ **គ.ជ.អ.ច.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ **គ.ជ.អ.ច.**។

**មាត្រា៨ .-**

**គ.ជ.អ.ច.** អាចបង្កើតគណៈកម្មាធិការ ក្រុមការងារ ក្រុមអ្នកជំនាញការ ឬយន្តការដទៃទៀតសម្រាប់កិច្ចការតាមវិស័យជាក់លាក់ តាមការចាំបាច់។

**មាត្រា៩ .-**

**គ.ជ.អ.ច.** អាចមានទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការជាតិ ឬអន្តរជាតិនានាមួយចំនួន តាមការចាំបាច់។

**មាត្រា១០ .-**

**គ.ជ.អ.ច.** មានអគ្គលេខាធិការដ្ឋានមួយ ជាសេនាធិការសម្រាប់ដំណើរការការងារប្រចាំថ្ងៃ ហើយមានទីស្នាក់ការនៅក្រសួងបរិស្ថាន។

អគ្គលេខាធិការដ្ឋាន **គ.ជ.អ.ច.** ដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងមួយចំនួន តាមការចាំបាច់ ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ឬអនុក្រឹត្យ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន **គ.ជ.អ.ច.** ត្រូវកំណត់ដោយអនុក្រឹត្យ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

**មាត្រា១១.-**

**ក.ជ.អ.ច.** មានសិទ្ធិប្រើប្រាស់រូបសញ្ញានិងត្រារបស់ខ្លួនដាច់ដោយឡែក។

## ជំពូកទី៥
## ប្រភពធនធាន

**មាត្រា១២.-**

**ក.ជ.អ.ច.** មានថវិកាដោយឡែករបស់ខ្លួន ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងបរិស្ថាន។

**ក.ជ.អ.ច.** មានសិទ្ធិទទួល គ្រប់គ្រង និងប្រើប្រាស់មូលនិធិ ដែលបានមកពីប្រភពផ្សេងៗ សម្រាប់ដំណើរការការងាររបស់ខ្លួន ស្របតាមនីតិវិធីច្បាប់ជាធរមាន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៣.-**

ព្រះរាជក្រឹត្យលេខ នស/រកត/១០១២/៩២៥ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៤.-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៥

៣៣៧.១៥០៥.៤០៦

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ: ៤៤៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សយ សុខា**